00717616

E100/1

នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

| | |
|---|---|
| សំណុំរឿងលេខ: | ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អជសដ |
| ភាគីដាក់ឯកសារ: | ក្រុមមេធាវីការពារក្ដីរបស់ អៀង ធីរិទ្ធ |
| ដាក់ជូន: | អង្គជំនុំជម្រះសាលាដំបូង |
| ភាសាដើម: | អង់គ្លេស |
| កាលបរិច្ឆេទឯកសារ: | ថ្ងៃទី ២២ ខែកក្កដា ឆ្នាំ ២០១១ |

ឯកសារទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception): 22 / 07 / 2011
ម៉ោង (Time/Heure): 10:45
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: Ratanak

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះ: សាធារណៈ / Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

## ចម្លើយតបរបស់មេធាវីការពារក្ដីទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យអង្គជំនុំជម្រះសាលាដំបូងចាត់ទុកទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួម (JCE III) ជាទម្រង់នៃការទទួលខុសត្រូវជាជម្រើសម្យ៉ាងទៀត

---

**សហមេធាវីរបស់លោកស្រី អៀង ធីរិទ្ធ៖**
ផាត់ ពៅស៊ាង
Diana ELLIS, QC

**សហមេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណី៖**
ពេជ អង្គ
Elisabeth SIMONNEAU FORT

**ចៅក្រមអង្គជំនុំជម្រះសាលាដំបូង៖**
ចៅក្រម និល ណុន ប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យូ អុតារា
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម យ៉ា សុខន

**សហព្រះរាជអាជ្ញា៖**
ជា លាង
Andrew CAYLEY

I. **សេចក្តីផ្តើម**

១. នៅថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១០ អង្គបុរេជំនុំជម្រះបានចេញ "សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម" **(សាលដីការបស់អង្គបុរេជំនុំជម្រះ)** ដែលក្នុងនោះអង្គបុរេជំនុំជម្រះបានសម្រេចថា ទម្រង់ទូលាយនៃសហឧក្រិដ្ឋកម្មរួម (JCE III) មិនត្រូវបានទទួលស្គាល់ជាទម្រង់នៃការទទួលខុសត្រូវ ដែលអាចអនុវត្តបានចំពោះការរំលោភបំពានលើច្បាប់មនុស្សធម៌អន្តរជាតិឡើយ[១]។

២. នៅក្នុងដីកាដំណោះស្រាយ សហចៅក្រមស៊ើបអង្កេតបានសម្រេចថា ទម្រង់ទីមួយនៃសហឧក្រិដ្ឋកម្មរួម (JCE I) និងទម្រង់ទីពីរ (JCE II) គឺជាទម្រង់នៃការទទួលខុសត្រូវព្រហ្មទណ្ឌដូចមានចែងនៅក្នុងមាត្រា ២៩ (ថ្មី) នៃច្បាប់ អ.វ.ត.ក ដែលបានបង្កើតជាផ្នែកមួយនៃច្បាប់អន្តរជាតិដែលអាចអនុវត្តបាននៅក្នុងប្រទេសកម្ពុជានៅក្នុងពេលពាក់ព័ន្ធ[២]។ សហចៅក្រមស៊ើបអង្កេតបានយល់ឃើញថែមទៀតថា ទម្រង់ជាលក្ខណៈប្រព័ន្ធនៃទម្រង់ទីពីរនៃសហឧក្រិដ្ឋកម្មរួម (JCE II) មិនត្រូវបានយកធ្វើជាមូលដ្ឋានឡើយ រីឯទម្រង់បឋមនៃទម្រង់ទីមួយនៃសហឧក្រិដ្ឋកម្មរួម (JCE I) អាចកំណត់យ៉ាងពេញលេញនូវការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់ជនត្រូវចោទ ចំពោះឧក្រិដ្ឋកម្មដែលបានរៀបរាប់នៅក្នុងដីកាដំណោះស្រាយ[៣]។ មេធាវីការពារក្តីលោកស្រី អៀង ធីរិទ្ធ **(មេធាវីការពារក្តី)** បានប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ប៉ុន្តែមិនបានលើកឡើងនូវបញ្ហានៃការគ្មានយុត្តាធិការសម្រាប់សហឧក្រិដ្ឋកម្មរួម (JCE) ដែលជាទម្រង់នៃការទទួលខុសត្រូវនោះទេ ពីព្រោះអង្គបុរេជំនុំជម្រះបានសម្រេចលើបញ្ហានេះរួចហើយ[៤]។

---

[១] សាលដីការបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះ ការអនុវត្តសហឧក្រិដ្ឋកម្មរួម (JCE) ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១០ ឯកសារលេខ D97/15/9 កថាខណ្ឌ ៧៧។

[២] ដីកាដំណោះស្រាយរបស់ ក.ស.ច.ស ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ ឯកសារលេខ D427 កថាខណ្ឌ ១៣១៨។

[៣] ដីកាដំណោះស្រាយរបស់ ក.ស.ច.ស ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ ឯកសារលេខ D427 កថាខណ្ឌ ១៥៤១។

[៤] បណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី អ្នកស្រី អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១០ ឯកសារលេខ D427/2/1 កថាខណ្ឌ ៨០។

៣. នៅថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណុំរឿង ០០២[៥]។ នៅថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងដល់ភាគីនានាថា កាលបរិច្ឆេទចុងក្រោយសម្រាប់ការដាក់អញ្ញត្រកម្ម គឺថ្ងៃច័ន្ទ ទី ១៤ ខែ កុម្ភៈ អនុលោមតាមវិធានផ្ទៃក្នុង ៨០(១) និង(២) និងវិធាន ៨៩[៦]។ ស្របតាមការជូនដំណឹងជាមុនរបស់អង្គជំនុំជម្រះសាលាដំបូង មេធាវីការពារក្តីបានដាក់បណ្តឹងជំទាស់ផ្នែកយុត្តាធិការនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង នៅថ្ងៃ ទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១១ រួមទាំងបណ្តឹងជំទាស់ទៅលើយុត្តាធិការរបស់ អ.វ.ត.ក ក្នុងការកាត់ទោសជនជាប់ចោទដោយផ្អែកលើមូលដ្ឋាននៃសហឧក្រិដ្ឋកម្មរួម (JCE)[៧]។ សហព្រះរាជអាជ្ញាមិនបានដាក់អញ្ញត្រកម្មណាមួយ នៅក្នុងក្របខណ្ឌពេលវេលាដែលបានចែងក្នុងវិធានផ្ទៃក្នុង ៨៩(១) នោះទេ។

៤. នៅថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១១ សហព្រះរាជអាជ្ញាបានដាក់ "សំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យអង្គជំនុំជម្រះសាលាដំបូងចាត់ទុកសហកម្មឧក្រិដ្ឋកម្មរួម ទម្រង់ III ជាទម្រង់នៃការទទួលខុសត្រូវ ជាជម្រើសម្យ៉ាងទៀត" **(សំណើសុំរបស់ ក.ស.ព)**[៨] ដោយស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងចាត់ទុកថា ទម្រង់ទីបីនៃសហកម្មឧក្រិដ្ឋកម្មរួម (JCE III) គឺជាទម្រង់នៃការទទួលខុសត្រូវដែលមានសុពលភាព នៅ អ.វ.ត.ក និងសុំឱ្យអង្គជំនុំជម្រះសាលាដំបូងកំណត់បទចោទនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះជាថ្មីឡើងវិញនៅពេលចេញសាលក្រម ថាជាបទឧក្រិដ្ឋដែលត្រូវបានប្រព្រឹត្តអនុលោមតាមទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួម (JCE III)[៩]។

---

[៥] ដីកាបង្គាប់របស់អង្គជំនុំជម្រះសាលាដំបូងឱ្យភាគីដាក់សម្ភារៈដើម្បីរៀបចំសវនាការ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១១ ឯកសារលេខ E9។

[៦] ការជូនដំណឹងជាមុនរបស់អង្គជំនុំជម្រះសាលាដំបូងអំពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ទាក់ទងនឹងឯកសារដែលមានលេខ E14, E15, E9/2, E9/3, E24 និង E27 ចុះថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១១ ឯកសារលេខ E35។

[៧] អញ្ញត្រកម្មរបស់មេធាវីការពារក្តីអ្នកស្រី អៀង ធីរិទ្ធ ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១១ ឯកសារលេខ E44 កថាខណ្ឌ ៣៣ ដល់ ៣៨។

[៨] សំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យអង្គជំនុំជម្រះសាលាដំបូងចាត់ទុកសហកម្មឧក្រិដ្ឋកម្មរួមទម្រង់ III ជាទម្រង់នៃការទទួលខុសត្រូវ ជាជម្រើសម្យ៉ាងទៀត ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១១ ឯកសារលេខ E100។

[៩] សំណើសុំរបស់ ក.ស.ព កថាខណ្ឌ ៤១។

៥. នៅថ្ងៃទី ២០ ខែមិថុនា ឆ្នាំ ២០១១ មេធាវីការពារក្តីបានទទួលដំណឹងពីអង្គជំនុំជម្រះសាលាដំបូង ថា កាលបរិច្ឆេទចុងក្រោយសម្រាប់ការដាក់ចម្លើយតបទៅនឹងសំណើសុំរបស់ ក.ស.ព ត្រូវបានពន្យារពេលរហូតដល់ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១[១០]។ ជាមួយគ្នានេះ មេធាវីការពារក្តីបានដាក់ចម្លើយតបរបស់ខ្លួនទៅនឹងសំណើសុំរបស់ស ក.ស.ព។

## II. **បញ្ញត្តិច្បាប់**

៦. មេធាវីការពារក្តីបានលើកឡើងថា បញ្ញត្តិច្បាប់ទាំងឡាយខាងក្រោមនេះ គឺជាប់ពាក់ព័ន្ធនៅក្នុងការសម្រេចលើសំណើសុំជាមូលដ្ឋាន៖

**មាត្រា ៣៥ នៃច្បាប់ អ.វ.ត.ក - សិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌**

នៅក្នុងការចោទប្រកាន់មកលើខ្លួន ជនជាប់ចោទមានសិទ្ធិទទួលបាននូវការធានាជាអប្បបរមា និងស្មើៗគ្នា យោងតាមមាត្រា ១៤ នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិ នយោបាយ។

ក. ទទួលព័ត៌មានភ្លាមៗ និងលម្អិតជាភាសាដែលខ្លួនយល់បានអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ចំពោះខ្លួន។

ខ. មានពេលវេលានិងលក្ខណៈគ្រប់គ្រាន់ដើម្បីរៀបចំខ្លួន និងទាក់ទងជាមួយមេធាវីរបស់ខ្លួនដែលជ្រើសរើសដោយខ្លួនឯង។

**វិធានផ្ទៃក្នុង ៨៩ - អញ្ញត្រកម្ម**

១. អញ្ញត្រកម្មទាក់ទងទៅនឹង:

ក- យុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូង

---

[១០] បានបញ្ជាក់នៅក្នុង សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើសុំពន្យារពេល ចុះថ្ងៃទី ៧ ខែ កក្កដា ឆ្នាំ ២០១១ ឯកសារលេខ E107។

ខ- ការរលត់បណ្តឹងអាជ្ញា

គ- មោឃភាពនីតិវិធីដែលត្រូវបានធ្វើបន្ទាប់ពីមានដីកាដំណោះស្រាយ

ត្រូវលើកឡើងយ៉ាងយូរ៣០ (សាមសិប)ថ្ងៃ ក្រោយពីដីកាដំណោះស្រាយចូលជាស្ថាពរ បើមិនដូច្នេះទេ អញ្ញត្រកម្មនោះមិនអាចត្រូវបានទទួលយកឡើយ ។

២. អង្គជំនុំជម្រះសាលាដំបូងត្រូវផ្តល់ឱ្យភាគីម្ខាងទៀតនូវឱកាសឆ្លើយតបទៅនឹងអញ្ញត្រកម្ម។

៣. អង្គជំនុំជម្រះសាលាដំបូងត្រូវសម្រេចជាបន្ទាន់អំពីអញ្ញត្រកម្មតាមសេចក្តីសម្រេចមួយដែលមានសំអាងហេតុ ឬ នៅពេលដំណាលគ្នានឹងសាលក្រមលើអង្គសេចក្តី។ ដំណើរការនីតិវិធីត្រូវបន្តលើកលែងតែអង្គជំនុំជម្រះចេញសេចក្តីសម្រេចភ្លាម ដែលមានអានុភាពបញ្ចប់កិច្ចដំណើការនីតិវិធី។

**វិធានផ្ទៃក្នុង ៩២ - ការដាក់សេចក្តីសន្និដ្ឋានរហូតដល់ពេលបិទកិច្ចពិភាក្សាដេញដោល**

រហូតទល់នឹងការបិទកិច្ចពិភាក្សាដេញដោល ភាគីអាចធ្វើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរដូចមានចែងនៅក្នុងសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ។ ក្រឡាបញ្ជីនៃអង្គជំនុំជម្រះត្រូវចុះហត្ថលេខា និងចុះកាលបរិច្ឆេទទទួលសេចក្តីសន្និដ្ឋាននេះ ហើយត្រូវដាក់បញ្ចូលទៅក្នុងសំណុំរឿង។

**វិធាន ៩៨(២)**

សាលក្រមត្រូវសម្រេចត្រឹមតែអង្គហេតុទាំងឡាយណា ដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះប៉ុណ្ណោះ ។ អង្គជំនុំជម្រះអាចផ្លាស់ប្តូរការកំណត់បទចោទ ដែលបានកំណត់ក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះបាន ប៉ុន្តែមិនអាចបញ្ចូលនូវធាតុផ្សំថ្មីនៃបទចោទបានឡើយ ។ អង្គជំនុំជម្រះត្រូវធ្វើការវិនិច្ឆ័យតែចំពោះជនជាប់ចោទប៉ុណ្ណោះ។ ប្រសិនបើបុគ្គលណាមួយ ដែលមកបង្ហាញ

ខ្លួនក្នុងពេលជំនុំជម្រះក្នុងឋានៈជាសាក្សី ត្រូវបានសង្ស័យថាបានប្រព្រឹត្តបទឧក្រិដ្ឋណាមួយ ឬបានសមគំនិតក្នុងការប្រព្រឹត្តបទឧក្រិដ្ឋ អង្គជំនុំជម្រះនឹងធ្វើការជំនុំជម្រះលើបុគ្គលនោះបាន លុះត្រាតែនៅក្រោយពេលដែលជននោះត្រូវបានចោទប្រកាន់ និងមានដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដូចចែងនៅក្នុងវិធានផ្ទៃក្នុងនេះប៉ុណ្ណោះ។

## III. ភាពមិនអាចទទួលយកបាននៃសំណើសុំរបស់ ក.ស.ព

### ៣.១ មិនអាចទទួលយកបានៈ អញ្ញត្រកម្ម

៧. មេធាវីការពារក្តីបានលើកឡើងថា សំណើសុំរបស់ ក.ស.ព បង្កើតជាអញ្ញត្រកម្មមួយ។ ហេតុនេះ សំណើនេះមិនអាចទទួលយកបានទេនៅដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីនេះ។ អង្គបុរេជំនុំជម្រះបានកំណត់អំពីអ្វីដែលបង្កើតបានជា "បណ្តឹងជំទាស់ផ្នែកយុត្តាធិការ" ហើយការជំទាស់នោះរួមបញ្ចូលនូវ "បណ្តឹងជំទាស់ [...] អត្ថិភាពនៃទម្រង់នៃការទទួលខុសត្រូវ ឬការទទួលស្គាល់ទម្រង់នោះតាមច្បាប់ទំនៀមទម្លាប់នៅពេលដែលចោទប្រកាន់"[១១]។ ម្យ៉ាងវិញទៀត ការស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងចាត់ទុកទម្រង់នៃការទទួលខុសត្រូវ ដែលត្រូវបានអង្គបុរេជំនុំជម្រះបដិសេធថាមិនមានក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅពេលប្រព្រឹត្តបទឧក្រិដ្ឋដែលបានលើកឡើង ថាជាទម្រង់នៃការទទួលខុសត្រូវដែលមានសុពលភាពដែលអាចអនុវត្តបាន នៅចំពោះមុខ អ.វ.ត.ក គឺបង្កើតបានជាការជំទាស់ផ្នែកយុត្តាធិការ។ សំណើសុំជាមូលដ្ឋាន របស់សហព្រះរាជអាជ្ញា បង្កើតបានជាអញ្ញត្រកម្មដូចមានចែងនៅក្នុងវិធានផ្ទៃក្នុង ៨៩(១)(ក) ពាក់ព័ន្ធនឹងយុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូង ដូចដែលបានរៀបរាប់នៅក្នុងដីកាដំណោះស្រាយដែលត្រូវបានធ្វើការកែប្រែ។ សហព្រះរាជអាជ្ញាស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូង ផ្លាស់ប្តូរយុត្តាធិការទៅលើទម្រង់នៃការទទួលខុសត្រូវ ទៅតាមវិធីដែលយុត្តាធិការត្រូវបានពង្រីកទៅជាទម្រង់ថ្មីនៃការ

---

[១១] សាលដីការបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកា ដំណោះស្រាយ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១១ ឯកសារលេខ D427/2/15 កថាខណ្ឌ ៦០។

ទទួលខុសត្រូវ ពោលគឺ ទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួម (JCE III)។

៨. នៅថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១១ នៅក្នុង "ការជូនដំណឹងជាមុនអំពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ទាក់ទងនឹងឯកសារដែលមានលេខ E14, E15, E9/2, E9/3, E24 និង E27" របស់ខ្លួន [១២] អង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងដល់ភាគីនានាថា កាលបរិច្ឆេទចុងក្រោយសម្រាប់ការដាក់អញ្ញត្រកម្មគឺថ្ងៃ ច័ន្ទ ទី ១៤ ខែ កុម្ភៈ ពីព្រោះ អនុលោមតាមដីកាបង្គាប់ឱ្យភាគីដាក់សម្ភារៈដើម្បីរៀបចំសវនាការ រយៈពេលកំណត់ដូចមានចែងក្នុងវិធានផ្ទៃក្នុង ៨០(១) និង (២) និងវិធាន ៨៩ គឺចាប់ផ្តើមរាប់ពីថ្ងៃ សុក្រ ទី ១៤ ខែ មករា ឆ្នាំ ២០១១។ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ច្បាស់លាស់ថា អង្គជំនុំជម្រះនឹងបដិសេធនូវរាល់សំណើទាំងអស់ដែលស្នើសុំឱ្យអនុម័តយកនូវនីតិវិធីថ្មីមួយដែលខុសពីនីតិវិធីដែលមានចែងនៅក្នុងវិធានផ្ទៃក្នុងបច្ចុប្បន្ន [១៣]។

៩. សហព្រះរាជអាជ្ញាមិនបានដាក់អញ្ញត្រកម្មណាមួយមុនថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១១ នោះទេ ដូច្នេះហើយ សហព្រះរាជអាជ្ញាមិនបានលើកឡើងនូវការជំទាស់ផ្នែកយុត្តាធិការឡើយ។ ហេតុនេះ សហព្រះរាជអាជ្ញាបានបង្ហាញអំពីការទទួលស្គាល់ការរៀបរាប់នៅក្នុងដីកាដំណោះស្រាយ ដែលត្រូវបានធ្វើការកែប្រែ ស្តីអំពីយុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូងលើបទឧក្រិដ្ឋនានាដែលត្រូវបានចោទប្រកាន់ និងទម្រង់នៃការទទួលខុសត្រូវនៃបទឧក្រិដ្ឋទាំងនោះ។ ពេលនេះ សហព្រះរាជអាជ្ញាមិនអាចត្រូវបានអនុញ្ញាតឱ្យធ្វើការអនុម័តគោលជំហរផ្សេង នៅដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីនេះទេ និងបានស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងពង្រីកបន្ថែមយុត្តាធិការរបស់ខ្លួន។ សហព្រះរាជអាជ្ញាត្រូវបានហាមឃាត់មិនឱ្យធ្វើសារណានេះទេ។ ពេលវេលាកំណត់សម្រាប់ការដាក់អញ្ញត្រកម្មបានកន្លងផុតទៅយូរហើយ រីឯសំណើសុំរបស់ ក.ស.ព គួរតែត្រូវបានបដិសេធចោលដោយផ្អែកលើមូលដ្ឋាននេះតែមួយប៉ុណ្ណោះ។ បន្ថែមពីលើនេះ អង្គជំនុំជម្រះសាលាដំបូងបានលើកឡើងយ៉ាងច្បាស់លាស់ នៅក្នុងការជូនដំណឹងជាមុនរបស់ខ្លួនថា រាល់ការប៉ុនប៉ងធ្វើវិសោធនកម្ម

---

[១២] ការជូនដំណឹងជាមុនរបស់អង្គជំនុំជម្រះសាលាដំបូងអំពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ទាក់ទងនឹងឯកសារដែលមានលេខ E14, E15, E9/2, E9/3, E24 និង E27 ចុះថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១១ ឯកសារលេខ E35។

[១៣] ការជូនដំណឹងជាមុនរបស់អង្គជំនុំជម្រះសាលាដំបូងអំពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ទាក់ទងនឹងឯកសារដែលមានលេខ E14, E15, E9/2, E9/3, E24 និង E27 ចុះថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១១ ឯកសារលេខ E35 ទំព័រទី២។

នីតិវិធីថ្មីខុសពីនីតិវិធីដែលមានចែងនៅក្នុងវិធាន៨៩ក្នុងបច្ចុប្បន្ន និង ត្រូវបានបដិសេធចោល។

១០. លើសពីនេះទៀត និងថ្វីបើសហព្រះរាជអាជ្ញាត្រូវបានជូនដំណឹងអំពីគោលជំហររបស់មេធាវីការពារក្តីតាមរយៈ "ការអង្កេតរបស់ អៀង សារី ចំពោះការជូនដំណឹងរបស់សហព្រះរាជអាជ្ញាអំពីបញ្ហាច្បាប់ដែលសហព្រះរាជអាជ្ញាមានបំណងលើកនៅសវនការបឋម" ក៏ដោយ[១៤] ក៏សហព្រះរាជអាជ្ញាខកខានមិនបានផ្តល់យុត្តិកម្មសម្រាប់ការដាក់អញ្ញត្រកម្ម នៅដំណាក់កាលចុងក្រោយបង្អស់នោះដែរ[១៥]។ នៅក្នុងសំណើសុំរបស់ ក.ស.ព សហព្រះរាជអាជ្ញាគ្រាន់តែបានអះអាងនៅក្នុងជើងទំព័រថា ការលើកឡើងរបស់ខ្លួនមិនមែនជា "ការជំទាស់" នោះទេ និងថា ការកំណត់បទចោទនៃអង្គហេតុជាថ្មីឡើងវិញ មិនមែនជាបញ្ហាផ្នែកយុត្តាធិការនោះឡើយ[១៦] ដោយពុំបានផ្តល់យុត្តិកម្ម ឬធ្វើការពន្យល់ភាគីនានាថែមទៀតឡើយ។ ការខកខាននេះបង្ហាញថា សហព្រះរាជអាជ្ញាបានសម្រេចមិនលើកឡើងពីបញ្ហានេះឲ្យបានទាន់ពេលវេលាដោយចេតនា ដូច្នេះ សំណើសុំត្រូវតែមិនអាចទទួលយកបាន។

## ៣.២ មិនអាចទទួលយកបាន: ពុំមានមូលដ្ឋានគតិយុត្តិសម្រាប់សំណើសុំរបស់ ក.ស.ព

១១. លើសពីនេះទៀត សំណើសុំរបស់ ក.ស.ព អះអាងថា សំណើសុំរបស់ខ្លួនស្ថិតនៅក្នុងក្របខ័ណ្ឌនៃវិធានផ្ទៃក្នុង ៩៨(២)[១៧]។ មេធាវីការពារក្តីបដិសេធការបកស្រាយនេះ។ អង្គជំនុំជម្រះត្រូវបានស្នើសុំឲ្យធ្វើការកែប្រែច្បាប់ រួមទាំងយុត្តាធិការរបស់អង្គជំនុំជម្រះលើទម្រង់នៃការទទួលខុសត្រូវដែលអាចអនុវត្តបាននៅ អ.វ.ត.ក ផងដែរ មិនគ្រាន់តែសុំឲ្យកែប្រែការកំណត់បទចោទនៃអង្គហេតុដូចដែលត្រូវបានអនុញ្ញាតអនុលោមតាមវិធានផ្ទៃក្នុង ៩៨(២) នោះទេ។ សំណើនេះត្រូវបានបង្ហាញ

---

[១៤] ការអង្កេតរបស់ អៀង សារី ចំពោះការជូនដំណឹងរបស់សហព្រះរាជអាជ្ញាអំពីបញ្ហាច្បាប់ដែលសហព្រះរាជអាជ្ញាមានបំណងលើកនៅសវនាការបឋម ចុះថ្ងៃទី ៣ ខែ ឧសភា ឆ្នាំ ២០១១ ឯកសារលេខ E9/30/1 កថាខណ្ឌ ៣ ដល់ ៦។

[១៥] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹង "សេចក្តីសង្កេតរបស់ អៀង សារី ចំពោះការជូនដំណឹងរបស់សហព្រះរាជអាជ្ញាអំពីបញ្ហាច្បាប់ដែលខ្លួនមានបំណងលើកឡើងនៅពេលសវនាការបឋម" ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១១ ឯកសារលេខ E9/30/2។

[១៦] សំណើសុំរបស់ ក.ស.ព ជើងទំព័រលេខ ១២។

[១៧] សំណើសុំរបស់ ក.ស.ព កថាខណ្ឌ ១ និង ៨។

តាមរយៈសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យអង្គជំនុំជម្រះសាលាដំបូង ទីមួយ *"ចាត់ទុក ថាទម្រង់សហឧក្រិដ្ឋកម្មរួម III គឺជាទម្រង់នៃការទទួលខុសត្រូវដែលមានសុពលភាពនៅ អ.វ.ត.ក"* និងបន្ទាប់មក *"សុំឱ្យកំណត់បទចោទនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះជាថ្មីឡើងវិញ តាមករណីសមស្រប នៅក្នុងពេលចេញសាលក្រមថាជាបទឧក្រិដ្ឋដែលត្រូវបានប្រព្រឹត្ត អនុលោមតាមទម្រង់ដែលពង្រីកបន្ថែមនៃសហឧក្រិដ្ឋកម្មរួមនៃ [JCE]"* [១៨]។ សំណើរបស់សហព្រះរាជអាជ្ញាលើកឡើងច្បាស់លាស់ថាជាដំបូងអង្គជំនុំជម្រះសាលាដំបូងចាំបាច់ត្រូវចាត់ទុកថា ទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួម (JCE III) ជាទម្រង់នៃការទទួលខុសត្រូវដែលមានសុពលភាព នៅ អ.វ.ត.ក ដើម្បីកំណត់បទចោទទាំងឡាយជាថ្មីឡើងវិញ។ លទ្ធភាពតែមួយគត់ដែលមានចែង នៅក្នុងវិធានផ្ទៃក្នុង ដើម្បីធ្វើឱ្យទម្រង់នៃការទទួលខុសត្រូវ "មានសុពលភាព" អាចអនុវត្តបាននៅ អ.វ.ត.ក គឺការដាក់បណ្តឹងជំទាស់ផ្នែកយុត្តាធិការ ស្របតាមវិធានផ្ទៃក្នុង ៨៩។ ដូច្នេះ មូលដ្ឋានគតិយុត្តិដែលសហព្រះរាជអាជ្ញាបានលើកឡើងសម្រាប់សំណើសុំរបស់ខ្លួនជាមូលដ្ឋាន ដែលគ្មានសុពលភាពទេ ហេតុនេះហើយ សំណើសុំរបស់ ក.ស.ព គួរតែត្រូវបានបដិសេធចោល។

## IV. **អំណះអំណាង**

### ៤.១ **"ការកំណត់បទចោទជាថ្មីឡើងវិញ" មិនអាចអនុញ្ញាតបានទេ**

១២. ដោយយោងលើវិធានផ្ទៃក្នុង ៩៨(២) សំណើសុំរបស់ ក.ស.ព បានសរសេរថា ក.ស.ព ស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូង *"កំណត់បទចោទនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះជាថ្មីឡើងវិញ ថាជាបទឧក្រិដ្ឋដែលត្រូវបានប្រព្រឹត្តអនុលោមតាម"* ទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួម (JCE III)[១៩]។ មេធាវីការពារក្តីអះអាងថា វិធានផ្ទៃក្នុង ៩៨(២) មិនអាចអនុញ្ញាតឱ្យមានការកំណត់ទម្រង់នៃការទទួលខុសត្រូវបានទេ។ មេធាវីការពារក្តីលើកឡើងថា វិធានផ្ទៃក្នុង ៩៨(២) មិនអនុញ្ញាតឱ្យមានការកំណត់ "បទចោទ" ជាថ្មីឡើងវិញទេ "ប៉ុន្តែ" អនុញ្ញាតឱ្យមានការកំណត់

---

[១៨] សំណើសុំរបស់ ក.ស.ព កថាខណ្ឌ ៤១។

[១៩] សំណើសុំរបស់ ក.ស.ព កថាខណ្ឌ ៤១។

"អង្គហេតុ" ជាថ្មីឡើងវិញ។ លើសពីនេះទៀត វិធានផ្ទៃក្នុង ៩៨(២) ហាមឃាត់មិនឲ្យមានការបញ្ចូលនូវធាតុផ្សំថ្មីនៃបទចោទឡើយ។ ទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួម (JCE III) ពង្រីកបន្ថែមទស្សនាទាននៃសហឧក្រិដ្ឋកម្មដើម្បីបង្កើតនូវការទទួលខុសត្រូវ នៅពេលដែលបទឧក្រិដ្ឋមួយដែលមិនត្រូវបានបញ្ចូលនៅក្នុងសហឧក្រិដ្ឋកម្មរួម គឺជា "ផលវិបាកដែលអាចស្មានដឹងជាមុននៃការអនុវត្តគម្រោងការរួម រីឯជនជាប់ចោទមិនកោតក្រែង ឬមិនអើពើនឹងហានិភ័យនោះទេ" [២០] ដូច្នេះវាជាការបញ្ចូលនូវធាតុផ្សំថ្មី។ ការកំណត់បទចោទជាថ្មីឡើងវិញដែលជនជាប់ចោទបានទទួលដឹងនៅពេលចេញសាលក្រម នឹងរំលោភលើសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបាននូវព័ត៌មានឆាប់រហ័សអំពីប្រភេទ និង មូលហេតុនៃការចោទប្រកាន់ចំពោះខ្លួន[២១]។

១៣. ប្រព័ន្ធច្បាប់កម្ពុជាមិនលើកឡើងពីការផ្លាស់ប្តូរចំពោះទម្រង់នៃការទទួលខុសត្រូវ ក្រោមច្បាប់របស់ខ្លួនឡើយ។ មាត្រា ៣៤៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា អនុញ្ញាតឲ្យតុលាការសម្រេចសេចក្តីតែលើប្រភេទនៃបទល្មើសដែលបានបង្ហាញនៅក្នុងដីកាបញ្ជូន ដែលបានចេញដោយសភាស៊ើបសួរប៉ុណ្ណោះ។ ការកំណត់បទល្មើសជាថ្មីឡើងវិញអាចធ្វើទៅបាន តែនៅចំពោះមុខសាលាឧទ្ធរណ៍ប៉ុណ្ណោះ ដោយកំណត់ថា សាលាឧទ្ធរណ៍មិនត្រូវបន្ថែមធាតុផ្សំថ្មីណាមួយដែលមិនបានដាក់ជូនតុលាការជាន់ដំបូងសម្រេចនោះទេ[២២]។ មេធាវីការពារក្តីរំលឹកថា អង្គជំនុំជម្រះសាលាដំបូងមិនជាប់កាតព្វកិច្ច ដោយសារការសម្រេចសេចក្តីរបស់ខ្លួននៅក្នុងសាលក្រមនៅក្នុងសំណុំរឿង ០០១ នោះទេ ជាពិសេសនៅពេលដែលភាគីទាំងឡាយនៅក្នុងសំណុំរឿង ០០១ មិនបានបង្ហាញពីបញ្ហាថា តើការកំណត់បទចោទជាថ្មីឡើងវិញអាចធ្វើបានស្របតាមវិធានផ្ទៃក្នុង ៩៨(២) ឬយ៉ាងណាឡើយ ដែលនេះជាចំណុចមួយដែលមេធាវីការពារក្តីសូមលើកឡើងនៅក្នុងចម្លើយតបរបស់ខ្លួន។

១៤. បញ្ញត្តិច្បាប់នៃតុលាការរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ (ICC) មានបទបញ្ញត្តិដែលស្រដៀងគ្នា

---

[២០] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Tadic* លេខសំណុំរឿង IT-94-1-A សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៩៩ កថាខណ្ឌ ២០៤។

[២១] វិធានផ្ទៃក្នុង ២១(១)(ឃ)។

[២២] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៤០១។

នឹងវិធានផ្ទៃក្នុង ៩៨(២) របស់ អ.វ.ត.ក។ បញ្ញត្តិច្បាប់ ៥៥ របស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ អនុញ្ញាតឲ្យអង្គជំនុំជម្រះសាលាដំបូងធ្វើការកំណត់អង្គហេតុស្តីអំពីរឿងក្តីមួយជាថ្មីឡើងវិញ នៅពេលចេញសាលក្រម។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍របស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ បានលើកឡើងយ៉ាងច្បាស់ថា ការផ្លាស់ប្តូរចំពោះការកំណត់អង្គហេតុដែលអាចធ្វើបាន មិនអាចពាក់ព័ន្ធនឹងការធ្វើកែប្រែចំពោះបទចោទជាផ្លូវការឡើយ[២៣]។ ជាការពិត "ការកែប្រែការកំណត់គតិយុត្តិ ត្រូវបានកម្រិតត្រឹមតែអង្គហេតុនានា និងស្ថានភាពនានាដែលបានរៀបរាប់នៅក្នុងការចោទប្រកាន់ និងការកែប្រែណាមួយចំពោះការចោទប្រកាន់នោះប៉ុណ្ណោះ" [២៤]។ ច្បាស់ណាស់ថា ការកំណត់ជាថ្មីឡើងវិញគួរតែត្រូវធ្វើទៅលើអង្គហេតុ មិនមែនទៅលើបទចោទ ដូចដែលសហព្រះរាជអាជ្ញាបានស្នើសុំនៅក្នុងសំណើសុំរបស់ ក.ស.ព នោះទេ។

១៥. នៅក្នុងករណីដែលអង្គជំនុំជម្រះសាលាដំបូងសម្រេចថា ការកំណត់គតិយុត្តិនៃបទចោទជាថ្មី ឡើងវិញត្រូវបានអនុញ្ញាតក្រោមវិធានផ្ទៃក្នុង ៩៨(២) ការកំណត់នេះត្រូវបំពេញលក្ខខណ្ឌចំនួនពីរៈ ទីមួយអង្គជំនុំជម្រះសាលាដំបូងត្រូវធានាថាការកំណត់ជាថ្មីឡើងវិញនេះនឹងមិននាំមកនូវការរំលោភលើសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌នោះឡើយ។ ទីពីរ ទម្រង់នៃការទទួលខុសត្រូវដែលបានលើកឡើង គឺអាចអនុវត្តបាននៅចំពោះមុខ អ.វ.ត.ក[២៥]។

---

[២៣] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង* *Thomas Lubanga Dyilo*, ICC-01/04-01/06 AO 15 AO 16 អង្គជំនុំជម្រះ សាលាឧទ្ធរណ៍ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក Lubanga Dyilo និងរដ្ឋអាជ្ញា ប្រឆាំងនឹងសេចក្តី សម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ។ ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៩ ដែលមានចំណងជើងថា "សេចក្តី សម្រេចផ្តល់ដំណឹងដល់ភាគីនានា និងអ្នកចូលរួមថា ការកំណត់បទចោទនៃអង្គហេតុអាចត្រូវផ្លាស់ប្តូរ យោងតាមបញ្ញត្តិច្បាប់ ៥៥(២) នៃបញ្ញត្តិច្បាប់របស់តុលាការ" **(សាលដីការបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍)** ចុះថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០០៩ កថាខណ្ឌ ៨៤។

[២៤] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Thomas Lubanga Dyilo* សាលដីការបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍ កថាខណ្ឌ ១០០ (ពួកយើងបានធ្វើការគូសបញ្ជាក់ហើយ)។

[២៥] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង កាំង ហ្គេកអ៊ាវ ហៅ ឌុច* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧/អវតក/អជសង សាលក្រម ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៤៩៦។ អំពីលក្ខខណ្ឌកំណត់ដែលថា ការកែប្រែដែលបានធ្វើលើអង្គហេតុមិនត្រូវរំលោភលើសិទ្ធិរបស់ជនជាប់ចោទ និងមិននាំឲ្យមានការជំនុំជម្រះក្តីដោយអយុត្តិធម៌ សូមមើល រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង* *Thomas Lubanga Dyilo* សាលដីការបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍ កថាខណ្ឌ ៧៧, ៨៥ និង ១០០។

មេធាវី ការពារក្តីរំលឹកថា ទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួម (JCE III) គឺជាទម្រង់នៃការទទួលខុសត្រូវដែលមិនអាចអនុវត្តបាននៅចំពោះមុខ អ.វ.ត.ក នោះទេ។ អង្គបុរេជំនុំជម្រះបាន លើកឡើងកាលពីមុនថា ទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួម (JCE III) មិនអាចអនុវត្តនៅចំពោះមុខ អ.វ.ត.កបានទេ ពីព្រោះទម្រង់នៃការទទួលខុសត្រូវនេះមិនមានក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅពេលប្រព្រឹត្តបទឧក្រិដ្ឋដែលបានចោទប្រកាន់នោះឡើយ។ ដីកាដំណោះស្រាយបាន ចោទប្រកាន់ជនជាប់ចោទដោយផ្អែកលើមូលដ្ឋាននៃទម្រង់ទីមួយនៃសហឧក្រិដ្ឋកម្មរួម (JCE I) តែប៉ុណ្ណោះ។ ការកំណត់បទចោទជាថ្មីឡើងវិញនៅពេលចេញសាលក្រម និងការចោទប្រកាន់ ជនជាប់ចោទដោយប្រើទម្រង់នៃការទទួលខុសត្រូវដែលមិនមាននៅចន្លោះឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៩ នឹងរំលោភលើសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ចៀសមិនរួច។ មូលហេតុនេះហើយបានជាសហព្រះរាជអាជ្ញាបានស្នើនៅក្នុងសំណើសុំរបស់ ក.ស.ព សុំឱ្យអង្គជំនុំជម្រះសាលាដំបូងធ្វើការប្រកាសអំពីសុពលភាពនៃទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួម (JCE III) ថាជាទម្រង់នៃការទទួលខុសត្រូវជាមុនសិន[២៦]។ ហេតុដូច្នេះ ការចាត ទុកទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួម (JCE III) ថាមាន "សុពលភាព"ជាទម្រង់នៃការទទួល ខុសត្រូវ ដែលត្រូវបានទទួលស្គាល់នៅចំពោះមុខ អ.វ.ត.ក គឺជាបុរេលក្ខខណ្ឌចាំបាច់មួយ មុនពេលកំណត់បទចោទជាថ្មីឡើងវិញប្រឆាំងនឹងជនជាប់ចោទ។ ដូចដែលបានអះអាងកាលពីមុន សំណើសុំរបស់ ក.ស.ព សុំឱ្យចាត់ទុកថាទម្រង់នៃការទទួលខុសត្រូវ មានសុពលភាពនៅ ចំពោះមុខ អ.វ.ត.ក មិនអាចទទួលយកបានទេ ពីព្រោះថិរវេលាបានផុតរលត់បាត់ទៅហើយ។ វិធានផ្ទៃក្នុង ៨៩(២) មិនអាចយកមកប្រើដើម្បីពិចារណាជាថ្មីឡើងវិញអំពីភាពអាចទទួលយកបាននៃទម្រង់នៃការទទួលខុសត្រូវនៅចំពោះមុខតុលាការមួយ ដែលបានសម្រេចកាលពីមុនរួច ហើយថា ទម្រង់នៃការទទួលខុសត្រូវនោះមិនអាចអនុវត្តបានទេ។

## ៤.២ ទឡ្ហីករណ៍សំខាន់ៗ

[២៦] សំណើសុំរបស់ ក.ស.ព កថាខណ្ឌ ៤១។

១៦. មេធាវីការពារក្ដីលើកឡើងថា ដោយផ្អែកលើមូលដ្ឋាននានានៃទឡ្ហីករណ៍ដែលលើកឡើងនៅពេលនេះ សំណើសុំរបស់ ក.ស.ព មិនអាចទទួលយកបានទេ និងគួរតែត្រូវបានបដិសេធចោលដោយសារតែគ្មានមូលដ្ឋានគតិយុត្តិ។ បច្ចុប្បន្ននេះ មេធាវីការពារក្ដីងាកមកគិតអំពីខ្លឹមសារនៃទឡ្ហីករណ៍វិញ ដើម្បីឆ្លើយតបទៅនឹងកថាខណ្ឌ ១២ ដល់កថាខណ្ឌ ៤០ នៃសំណើសុំរបស់ ក.ស.ព។

១៧. សហព្រះរាជអាជ្ញាបានតវ៉ានៅក្នុងសំណើសុំរបស់ ក.ស.ព ថា ទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួម **(JCE III)** ត្រូវបានទទួលស្គាល់ថាជាទម្រង់នៃការទទួលខុសត្រូវនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅចន្លោះឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩[២៧]។ សហព្រះរាជអាជ្ញាបានលើកឡើងនូវទឡ្ហីករណ៍របស់ខ្លួនដោយផ្អែកតែលើមូលដ្ឋាន "កម្មវត្ថុ និងគោលបំណងនៃធម្មនុញ្ញតុលាការអន្តរជាតិទីក្រុងនូរ៉ាំប៊ឺហ្គ និងការជំនុំជម្រះទោសក្រោយសង្គ្រាមលោកលើកទី២" [២៨] រឿងក្ដី *the Essen Lynching*[29] និងរឿងក្ដី*កោះ Borkum*[៣០] និងជាចុងក្រោយគឺ ឋានៈនៃទម្រង់ទីបី នៃសហឧក្រិដ្ឋកម្មរួម **(JCE III)** ជា "គោលការណ៍ទូទៅនៃច្បាប់" [៣១]។

១៨. មេធាវីការពារក្ដីបដិសេធការយោងលើកម្មវត្ថុ និងគោលបំណងនៃធម្មនុញ្ញតុលាការអន្តរជាតិនូរ៉ាំប៊ឺហ្គរបស់សហព្រះរាជអាជ្ញានៅពេលផ្ដល់សិទ្ធិអំណាចមួយ ដែលបង្ហាញភ័ស្ដុតាងថា ទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួម **(JCE III)** ដែលជាទម្រង់នៃការទទួលខុសត្រូវ មានដើមកំណើតនៅក្នុងអំឡុងពេលនោះ។ ដោយក្ដីគោរព មេធាវីការពារក្ដីបានយល់ស្របតាមការសម្រេចរបស់អង្គបុរេជំនុំជម្រះថា ធម្មនុញ្ញតុលាការអន្តរជាតិនូរ៉ាំប៊ឺហ្គមិនអាចប្រើប្រាស់ធ្វើជាមូលដ្ឋានដើម្បីបង្ហាញថា ទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួម **(JCE III)** មាននៅក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិ

---

[២៧] សំណើសុំរបស់ ក.ស.ព កថាខណ្ឌ ១៧ ដល់ ៣៧។

[២៨] សំណើសុំរបស់ ក.ស.ព កថាខណ្ឌ ២៣។

[២៩] សំណើសុំរបស់ ក.ស.ព កថាខណ្ឌ ២៤ ដល់ ២៦។

[៣០] សំណើសុំរបស់ ក.ស.ព កថាខណ្ឌ ២៧ ដល់ ២៨។

[៣១] សំណើសុំរបស់ ក.ស.ព កថាខណ្ឌ ២៩។

នៅក្នុងពេលវេលាពាក់ព័ន្ធនោះទេ[៣២]។

១៩. សហព្រះរាជអាជ្ញាបានផ្អែកលើ រឿងក្តី *the Essen Lynching* និងរឿងក្តី *កោះ Borkum* ថែមទៀត នៅពេលតវ៉ាថា ទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួម (JCE III) គឺជាផ្នែកមួយនៃច្បាប់ ទំនៀមទម្លាប់អន្តរជាតិនៅចន្លោះឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩។ តាមរយៈនេះ មេធាវីការពារក្តីបាន យោងទៅលើសំអាងហេតុរបស់អង្គបុរេជំនុំជម្រះដែលមាននៅក្នុងសាលដីការបស់អង្គបុរេជំនុំជម្រះ[៣៣]។ ដូចដែលអង្គបុរេជំនុំជម្រះបានសម្រេចយ៉ាងត្រឹមត្រូវហើយគឺថា រឿងក្តីទាំងពីរនោះខកខានមិនបានបង្ហាញភ័ស្តុតាងថា ទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួម (JCE III) មាននៅក្នុងអំឡុងពេលពាក់ព័ន្ធនោះទេ។ នៅពេលគ្មានសាលក្រមដែលមានបញ្ជាក់ហេតុផលនៅក្នុងរឿងក្តីណាមួយ ធ្វើឱ្យមានភាពមិនច្បាស់លាស់ពាក់ព័ន្ធនឹងមូលដ្ឋាននៃការទទួលខុសត្រូវ ដែលជាមូលដ្ឋានសំអាងដែលជនជាប់ចោទត្រូវបានផ្តន្ទាទោស[៣៤] និង ជាលទ្ធផល វាមិនអាចផ្តល់នូវប្រភពនៃច្បាប់ដែលគួរឱ្យជឿជាក់ និងយកជាការបាន ដែលសហព្រះរាជអាជ្ញាអាចធ្វើជាសំអាងដើម្បីបង្ហាញភ័ស្តុតាងថា ទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួម (JCE III) គឺជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅពេលនោះឡើយ។ តាមរយៈនេះ មេធាវីការពារក្តីបានយោងលើអំណះអំណាងកាលពីមុនរបស់ក្រុមមេធាវីការពារក្តី អៀង សារី ស្តីពីភាពមិនស៊ីសង្វាក់គ្នានៃរឿងក្តីនានាដែលអង្គជំនុំជម្រះសាលាឧទ្ធរណ៍ក្នុងរឿងក្តី *Tadic* បានយកធ្វើជាមូលដ្ឋានសម្រាប់សំអាងហេតុរបស់ខ្លួន[៣៥]។ សហព្រះរាជអាជ្ញាខ្លួនឯង បានទទួលស្គាល់ថា សាលក្រមនៅក្នុងរឿងក្តី *the Essen Lynching* មិនបញ្ជាក់ច្បាស់ពីទ្រឹស្តីនៃការទទួលខុសត្រូវ ទៅតាមអ្វីដែលតុលាការសម្រេចឱ្យជនជាប់ចោទ

---

[៣២] សាលដីការបស់អង្គបុរេជំនុំជម្រះ កថាខណ្ឌ ៧៨។

[៣៣] សំណើសុំរបស់ ក.ស.ព កថាខណ្ឌ ៧៩ ដល់ ៨១។

[៣៤] សាលដីការបស់អង្គបុរេជំនុំជម្រះ កថាខណ្ឌ ៧៩។

[៣៥] ពាក្យស្នើសុំរបស់លោក អៀង សារី ប្រឆាំងនឹងការអនុវត្តនៅ អ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវខាង ព្រហ្មទណ្ឌ ដែលគេហៅថា សហឧក្រិដ្ឋកម្មរួម (JCE) ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៨ ឯកសារលេខ D97 (ពាក្យស្នើសុំរបស់ អៀង សារី ស្តីពីសហឧក្រិដ្ឋកម្មរួម) កថាខណ្ឌ ១៨ ដល់ ១៩ និង ២៤។ សេចក្តីសង្កេតបន្ថែម របស់លោក អៀង សារី ស្តីពីការអនុវត្តទ្រឹស្តីសហកម្មឧក្រិដ្ឋកម្មរួម នៅ អ.វ.ត.ក ចុះថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ឯកសារលេខ D97/7 កថាខណ្ឌ ៤៧, ៤៩និង ៥៤។

ម្នាក់ៗត្រូវទទួលខុសត្រូវពីអ្វីនោះឡើយ[៣៦] និងទទួលស្គាល់ថា គ្មានចៅក្រមណាម្នាក់បញ្ជាក់ពីអង្គច្បាប់នៅក្នុងរឿងក្តី *កោះ Borkum* នោះទេ[៣៧]។ សហព្រះរាជអាជ្ញាមិនអាចគ្រាន់តែ "លើកឡើង" ថា រឿងក្តី *កោះ Borkum* គាំទ្រទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួម(JCE III) ឡើយ[៣៨]។

២០. សហព្រះរាជអាជ្ញាបានលើកឡើងថា ការទទួលខុសត្រូវទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួម(JCE III) អាចត្រូវបានបង្ហាញនៅក្នុងច្បាប់អន្តរជាតិនៅក្នុងអំឡុងពេលពាក់ព័ន្ធ "ដោយសារតែឋានៈ របស់វាជា "គោលការណ៍ទូទៅនៃច្បាប់"" ពីព្រោះយុត្តាធិការជាតិជាច្រើនបានទទួលស្គាល់ទម្រង់នៃការរួមប្រព្រឹត្តបទឧក្រិដ្ឋដែលស្រដៀងទៅនឹងទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួម (JCE III)[៣៩]។ មេធាវីការពារក្តីបានផ្អែកលើសំអាងហេតុរបស់អង្គបុរេជំនុំជម្រះ ដែលមាននៅក្នុងសាលដីការបស់អង្គបុរេជំនុំជម្រះ ជាថ្មីម្តងទៀត[៤០]។ មេធាវីការពារក្តីលើកឡើងថា អង្គបុរេជំនុំជម្រះបានយល់ឃើញយ៉ាងត្រឹមត្រូវថា រឿងក្តីក្នុងស្រុកនានាដែលត្រូវបានយោងនៅក្នុងរឿងក្តី *Tadic* និងត្រូវបានដកស្រង់ដោយសហព្រះរាជអាជ្ញានៅក្នុងសំណើសុំរបស់ ក.ស.ព មិនមែនជា "ករណីយុត្តិសាស្ត្រដ៏ត្រឹមត្រូវ សម្រាប់គោលបំណងក្នុងការសម្រេចអំពីឋានៈនៃច្បាប់ទំនៀមទម្លាប់ នៅក្នុងផ្នែកនេះឡើយ"[៤១] និង "មិនអាចត្រូវបានយកមកធ្វើជាសំអាងថាជាភស្តុតាងដែល មិនអាចបដិសេធបាននៃគោលការណ៍ ឬវិធានអន្តរជាតិឡើយ តាមទ្រឹស្តីដែលគោលការណ៍ច្បាប់ ទូទៅត្រូវបានទទួលស្គាល់ដោយបណ្តាប្រជាជាតិនៅលើពិភពលោក"[៤២]។

២១. សហព្រះរាជអាជ្ញាបានណែនាំឱ្យអង្គជំនុំជម្រះសាលាដំបូង ស្នើសុំសារណារបស់អ្នកដែលមិនមែន

---

[៣៦] សំណើសុំរបស់ ក.ស.ព កថាខណ្ឌ ២៦។

[៣៧] សំណើសុំរបស់ ក.ស.ព កថាខណ្ឌ ២៨។

[៣៨] សំណើសុំរបស់ ក.ស.ព កថាខណ្ឌ ២៨។

[៣៩] សំណើសុំរបស់ ក.ស.ព កថាខណ្ឌ ២៩។

[៤០] សាលដីការបស់អង្គបុរេជំនុំជម្រះ កថាខណ្ឌ ៨២ ដល់ ៨៧។

[៤១] សាលដីការបស់អង្គបុរេជំនុំជម្រះ កថាខណ្ឌ ៨២។

[៤២] សាលដីការបស់អង្គបុរេជំនុំជម្រះ កថាខណ្ឌ ៨៥។ សូមមើលផងដែរ សាស្ត្រាចារ្យបណ្ឌិត K. Ambos សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី ពាក់ព័ន្ធនឹងសំណុំរឿងព្រហ្មទណ្ឌ ០០១/១៨-០៧-២០០៧-អវតក/កសចស (អបជ ០២) ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៨ ឯកសារលេខ D99/3/27 ទំព័រ ២៩ ដល់ ៣០។

ជាភាគីនៃរឿងក្តី ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងសម្រេចថា ទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួម (JCE III) មិនបង្កើតបានជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅក្នុងអំឡុងពេលដែលពាក់ព័ន្ធទេនោះ[៤៣]។ មេធាវីការពារក្តីរំលឹកថា សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តីត្រូវបានស្នើសុំនៅចំពោះមុខ អ.វ.ត.ក អំពីការរីកចម្រើនទ្រឹស្តីនៃសហឧក្រិដ្ឋកម្មរួម និងការវិវត្តនិយមន័យនៃទម្រង់នៃការទទួលខុសត្រូវនេះ ដោយសំដៅជាពិសេសទៅលើអំឡុងពេលចន្លោះឆ្នាំ ១៩៧៥ និងឆ្នាំ ១៩៧៩ និងការយោងជាពិសេសពាក់ព័ន្ធទៅនឹងបញ្ហាថា តើសហឧក្រិដ្ឋកម្មរួមដែលជាទម្រង់នៃការទទួលខុសត្រូវមួយអាចអនុវត្តបាននៅចំពោះមុខ អ.វ.ត.ក ដែរឬយ៉ាងណា បន្ទាប់ពីធ្វើការពិចារណាទៅលើអង្គហេតុដែលថា បទឧក្រិដ្ឋនានាត្រូវបានប្រព្រឹត្តឡើងនៅ ចន្លោះឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩[៤៤]។ ការស្នើសុំសារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តីស្តីអំពីកម្មវត្ថុដដែល នឹងជាការខ្ជះខ្ជាយពេលវេលា និងមិនចាំបាច់ នៅដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីនេះ ជាពិសេសដោយសារតែបញ្ហានៃភាពអាចទទួលយកបាននៃសហឧក្រិដ្ឋកម្មរួមត្រូវបានជជែកតវ៉ាគ្នាយ៉ាងខ្លាំងរួចមកហើយនៅចំពោះមុខអង្គបុរេជំនុំជម្រះ។ សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តីមិនគួរត្រូវបានចាត់ទុកជាបញ្ហាគតិយុត្ត ដែលចៅក្រមនានាអាចយល់បានឡើយ។ ការស្វែងរកការយល់ឃើញរបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តីនៅដំណាក់កាលនេះ នឹងនាំឱ្យមានការពន្យារពេលថែមទៀត ហើយនឹងនាំមកនូវភាពអយុត្តិធម៌ដល់ជនជាប់ចោទ។

២២. សហព្រះរាជអាជ្ញាក៏បានលើកជាទឡ្ហីករណ៍ផងដែរថា ទ្រឹស្តីទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួម(JCE III) "មានភាពស៊ីសង្វាក់គ្នាជាមួយកម្មវត្ថុ និងគោលបំណងនៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ" [៤៥]។ បញ្ហាថាតើទ្រឹស្តី ទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួម(JCE III) គឺជា "យន្តការសមស្រប

---

[៤៣] សំណើសុំរបស់ ក.ស.ព កថាខណ្ឌ ៣១។

[៤៤] សេចក្តីអញ្ជើញអ្នកដែលមិនមែនជាភាគីនៃរឿងក្តីរបស់អង្គបុរេជំនុំជម្រះ សំណុំរឿងព្រហ្មទណ្ឌ ០០១/១៨-០៧-២០០៧-អវតក/កសចស (អបជ ០២) ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ឯកសារលេខ D99/3/13 និង D99/3/14។ សេចក្តីអញ្ជើញអ្នកដែលមិនមែនជាភាគីនៃរឿងក្តីរបស់អង្គបុរេជំនុំជម្រះ សំណុំរឿងព្រហ្មទណ្ឌ ០០១/១៨-០៧-២០០៧-អវតក/កសចស (អបជ ០២) ចុះថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០០៨ ឯកសារលេខ D99/3/12។

[៤៥] សំណើសុំរបស់ ក.ស.ព កថាខណ្ឌ ៣៨ ដល់ ៤០។

និងចាំបាច់មួយសម្រាប់ លើកឡើងពីការគំរាមកំហែងពិសេសនានាដែលបង្កដោយឧក្រិដ្ឋភាពដែលគេបានរៀបចំទុក" ឬយ៉ាងណា[៤៦] ឬបញ្ហាថាតើ សហគមន៍ពិភពលោកមានការចាប់អារម្មណ៍យកចិត្តទុកដាក់ខ្លាំងក្នុងការកាត់ទោសបុគ្គលនានាអំពីទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួម(JCE III) ឬយ៉ាងណា[៤៧] គឺមិនមានការពាក់ព័ន្ធទេនៅពេលនេះ។ គោលការណ៍ជាមូលដ្ឋានដែលគេចាំបាច់ត្រូវគោរពនោះ គឺគោលការណ៍នីត្យានុកូលភាពដែលបង្ហាញថា ជនជាប់ចោទមិនគួរត្រូវបានចោទប្រកាន់អំពីបទឧក្រិដ្ឋមួយនិងអំពីទម្រង់នៃការទទួលខុសត្រូវដែលមិនមាននៅពេលប្រព្រឹត្តបទឧក្រិដ្ឋដែលបានចោទប្រកាន់ឡើយ។ ទឡ្ហីករណ៍របស់សហព្រះរាជអាជ្ញា ដែលបានកើនឡើងដោយផ្អែកលើមូលដ្ឋាននៃ "ភាពចាំបាច់" នៃការមានទ្រឹស្តីនៃទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួម(JCE III) ដែលត្រូវបានទទួលស្គាល់ដោយសហគមន៍អន្តរជាតិទាំងមូល គួរតែត្រូវបានបដិសេធចោល ដោយអង្គជំនុំជម្រះសាលាដំបូង។

២៣. ជាចុងក្រោយ សហព្រះរាជអាជ្ញាបានលើកឡើងថា ការអនុវត្តទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួម (JCE III) មិនបានពង្រីកវិសាលភាពនៃការទទួលខុសត្រូវខាងព្រហ្មទណ្ឌដោយមិនសមហេតុផល ឬ នាំឱ្យមានការចាត់ទុកជាបទឧក្រិដ្ឋនូវការប្រព្រឹត្ត ដែលពាក់ព័ន្ធនឹងពិរុទ្ធភាពដែលមានលក្ខណៈតូចតាច ដូចដែលគេបានលើកឡើងនោះឡើយ[៤៨]។ មេធាវីការពារក្តីបដិសេធទឡ្ហីករណ៍នេះ និងយោងលើតុលាការពិសេសសម្រាប់លីបង់ (STL) ដែលថ្មីៗនេះបានសម្រេចថា "វិធីសាស្ត្រល្អប្រសើរជាងនេះតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ គឺមិនមែនជាការការអនុញ្ញាតឱ្យមានការផ្តន្ទាទោសក្រោមទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួម (JCE III) សម្រាប់បទឧក្រិដ្ឋដែលមានចេតនាពិសេសនោះទេ [...]" និងថា បទឧក្រិដ្ឋទាំងនោះ គឺរួមបញ្ចូលនូវអំពើប្រល័យពូជសាសន៍ និងការធ្វើទុក្ខបុកម្នេញ ដែលជាប្រភេទបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ[៤៩]។ មេធាវីការពារក្តីក៏បានយោងលើសារណាកាលពីមុនរបស់ អៀង សារី ស្តីពីសហឧក្រិដ្ឋកម្មរួមដែលបង្ហាញថា

---

[៤៦] សំណើសុំរបស់ ក.ស.ព កថាខណ្ឌ ៣៩។

[៤៧] សំណើសុំរបស់ ក.ស.ព កថាខណ្ឌ ៣៨។

[៤៨] សំណើសុំរបស់ ក.ស.ព កថាខណ្ឌ ៤០។

[៤៩] តុលាការពិសេសសម្រាប់ឡេបាណុន STL-11-01/I សេចក្តីសម្រេចបន្ទាន់លើច្បាប់ជាធរមាន: អំពើភេរវកម្ម អំពើសមគំនិត អំពើមនុស្សឃាត ការប្រព្រឹត្តបទឧក្រិដ្ឋ ការចោទប្រកាន់ត្រួតលើគ្នា ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១១ កថាខណ្ឌ ២៤៩។

ទម្រង់នៃការទទួលខុសត្រូវនៃសហឧក្រិដ្ឋកម្មរួម មិនមានភាពច្បាស់លាស់ និងមានភាពប្រែប្រួល និងថា បញ្ហានេះត្រូវបានយកទៅពិភាក្សាច្រើនរវាងចៅក្រម និងអ្នកចេះដឹងជ្រៅជ្រះ[៥០]។

២៤. មេធាវីការពារក្តីលើកឡើងថា ភាពអាចអនុវត្តបាននៃទម្រង់សហឧក្រិដ្ឋកម្មរួមនៅក្នុងប្រទេសកម្ពុជា ចន្លោះពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ មិនមានអត្ថិភាពទេទាក់ទងទៅនឹងទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួម (JCE III) និងបានយោងលើសារណាកាលពីមុនរបស់ខ្លួនស្តីអំពីបញ្ហានេះ[៥១] ក៏ដូចជាសំអាងហេតុរបស់អង្គបុរេជំនុំជម្រះស្តីពីបញ្ហានេះផងដែរ[៥២]។ សហព្រះរាជអាជ្ញាខកខានមិនបានបង្ហាញថា ទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួម (JCE III) គឺជាទម្រង់នៃការទទួលខុសត្រូវមួយដែលមានក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅក្នុងពេលពាក់ព័ន្ធនោះទេ។

## III. សន្និដ្ឋាន

១. តាមហេតុផលដូចបានរៀបរាប់ខាងលើ មេធាវីការពារក្តីសូមគោរពស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងមេត្តា:

(១) យល់ឃើញថា សំណើសុំរបស់ ក.ស.ព មិនអាចទទួលយកបានទេ។

(២) ឬ ជាជម្រើសម្យ៉ាងទៀត បដិសេធសំណើសុំរបស់ ក.ស.ព ទាំងមូល។

---

[៥០] ពាក្យស្នើសុំរបស់ អៀង សារី ស្តីពីសហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៥។

[៥១] សារណារបស់អ្នកស្រី អៀង ធីរិទ្ធ ស្តីពីការអនុវត្តនៅ អ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវដែលគេស្គាល់ថា សហកម្មឧក្រិដ្ឋកម្មរួម អនុលោមតាមដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០០៨ ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៨ ឯកសារលេខ D97/3/2 កថាខណ្ឌ ២៤ ដល់ ២៧។ បណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តីរបស់អ្នកស្រី អៀង ធីរិទ្ធ ចំពោះ "ដីកាសម្រេចអំពីការអនុវត្តនៅ អ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវដែលត្រូវ បានទទួលស្គាល់ថាជាសហឧក្រិដ្ឋកម្មរួម" ចុះថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០០៩ ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១០ ឯកសារលេខ D97/15/1 កថាខណ្ឌ ៦៣ ដល់ ៧៥។

[៥២] សាលដីការបស់អង្គបុរេជំនុំជម្រះ កថាខណ្ឌ ៧៥ ដល់ ៨៩។

| ភាគី | កាលបរិច្ឆេទ | ឈ្មោះមេធាវី | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|---|
| សហមេធាវីការពារក្តី អៀង ធីរិទ្ធ | ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១ | ផាត់ ពៅស៊ាង<br>Diana ELLIS, QC | ភ្នំពេញ | |